ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សារលិខិតរំលែកមរណទុក្ខ

## គោរពជូន
## លោកជំទាវ សុខ លាង ព្រមទាំងក្រុមគ្រួសារ

**លោកជំទាវ ជាទីរាប់អាន!**

តាំងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំមានក្ដីក្ដុកក្ដួលក្រៃលែងពេលបានទទួលដំណឹងថា **ឯកឧត្តមនាយឧត្តមសេនីយ៍ សុខ សារឿន** រដ្ឋលេខាធិការក្រសួងការពារជាតិ ដែលត្រូវជាស្វាមីរបស់លោកជំទាវ បានទទួលមរណភាព កាលពីព្រឹកថ្ងៃពុធ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ១០:៤៥នាទី ក្នុងជន្មាយុ ៧៩ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់**ឯកឧត្តមនាយឧត្តមសេនីយ៍ សុខ សារឿន** គឺជាការបាត់បង់ដ៏គួរឱ្យសោកស្ដាយបំផុតនូវស្វាមី ឪពុក ជីតា ដែលប្រកបដោយព្រហ្មវិហារធម៌ និងជាការបាត់បង់នូវឥស្សរជនជាន់ខ្ពស់របស់ជាតិមួយរូប ដែលបានបូជាអស់កម្លាំងកាយ ចិត្ត បញ្ញា ស្មារតី និងបានលះបង់គ្រប់បែបយ៉ាងដើម្បីចូលរួមចំណែកក្នុងការតស៊ូ និងធ្វើពលិកម្មរំដោះជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ព្រមទាំងបានរួមចំណែកក្នុងការកសាងសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍ជាតិរហូតដល់ថ្ងៃអវសានជីវិត។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយក្ដីសោកសង្រេងបំផុតជាមួយ លោកជំទាវ ព្រមទាំងក្រុមគ្រួសារ និងសូមបួងសួងជូនវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ សុខ សារឿន** សូមអញ្ជើញទៅកាន់ឋានសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ព្រហស្បតិ៍ ៨រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវិថីអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh